# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ១៧៨/00១/២0១១

ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២0១១

**សេចក្តីសម្រេច**

លេខ : ១១៣/00១/២0១១ កបធ.ច

ចុះថ្ងៃទី 0១ ខែ កុម្ភៈ ឆ្នាំ២0១១

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/0៤៩៨/0៦ ចុះថ្ងៃទី 0៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១0៧/00៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២00៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ 0៦៩ រ.ស ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ២0១១ របស់ឯកឧត្តម **ខួន ញ៉ិល** ប្រធានរដ្ឋសភាស្តីទី ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២0១0 នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី២ នាថ្ងៃទី ២0 ខែមករា ឆ្នាំ២0១១ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ២0១១ វេលាម៉ោង ១៥ និង ៤៥ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ខួន សុដារី** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា ដែលចែងអំពីគោលដៅកំណត់ការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា និយមន័យនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា បញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពីការរៀបចំសមាជ មាន ៦ មាត្រា ចែងអំពីប្រធានសមាជ ទីកន្លែងប្រារព្ធធ្វើសមាជ សមាសភាពគណៈកម្មាធិការសមាជ មុខងាររបស់ប្រធានសមាជ អគ្គលេខាធិការដ្ឋានសមាជ និងបន្ទុកចំណាយសម្រាប់ដំណើរការសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពីការប្រព្រឹត្តទៅនៃសមាជ មាន ៤ មាត្រា ចែងអំពីឥស្សរជនដែលមានសិទ្ធិផ្តួចផ្តើមឱ្យមានការប្រជុំសមាជ ការកោះអញ្ជើញឱ្យចូលរួមប្រជុំសមាជ កូរ៉ុមនៃការប្រជុំសមាជ សំឡេងអនុម័តរបស់សមាជ តម្លៃនៃសេចក្តីសម្រេចរបស់សមាជ ការផ្សព្វផ្សាយ និង ការចុះក្នុងរាជកិច្ច ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៤ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា ចែងអំពីរយៈពេលនៃការកោះប្រជុំលើកដំបូងរបស់សមាជ ដើម្បីពិនិត្យ និង អនុម័តបទបញ្ជាផ្ទៃក្នុងរបស់សមាជ និង ការអនុវត្តបទបញ្ជាផ្ទៃក្នុងរដ្ឋសភាសម្រាប់ដំណើរការកិច្ចប្រជុំសមាជលើកដំបូង ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារទាំង៤ជំពូក ១៤មាត្រា នៃច្បាប់នេះ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា ១.** ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី២ នាថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**